ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១៦២.....សហវ.អគស

ថ្ងៃ ពុធ ៦កើត ខែ ចេត្រ ឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៩

## ដីកាបញ្ជូន

**គោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**

| ល.រ | ខ្លឹមសារឯកសារ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១. | អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជាស្របតាមនាមវលី នៃតារាងពន្ធគយសុខដុមរបស់អាស៊ានឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋប្រជាមានិតចិន។ | ១ច្បាប់ | ដើម្បីមុខការ |

សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យ និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមប្រតិភូ** ទទួលនូវការរាប់អានពីខ្ញុំ។

**អគ្គនាយក**
**នៃអគ្គនាយកដ្ឋានគោលនយោបាយ**

**ទេព ភិយ្យារិទ្ធ**

បណ្ឌិត **គុណ-ញឹម**
11-4-19

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ [illegible]

ថ្ងៃ [illegible] ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៩

| ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី | |
|---|---|
| ចូល | ថ្ងៃទី 28 ខែ 2 ឆ្នាំ 2019 |
| | ម៉ោង: 5:00 |

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ÷** សំណើសុំការយល់ព្រម និងចុះហត្ថលេខាលើអនុក្រឹត្យ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជាស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

**យោង÷**
- មាត្រា ៦ នៃច្បាប់ស្តីពីគយរបស់កម្ពុជា ដែលបានប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧។
- អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី២៧ មេសា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១២ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជាស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិនត្រូវបានបញ្ចប់ការផ្ទេរពីប្រព័ន្ធសុខដុម HS2012 ទៅប្រព័ន្ធសុខដុម HS2017 រួចហើយដោយទទួលការឯកភាពពីអន្តរក្រសួងពាក់ព័ន្ធ។ ការផ្ទេរកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយនេះ មិនមានផល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជានោះទេ ពីព្រោះការផ្ទេរនេះគ្រាន់តែជាការធ្វើបច្ចុប្បន្នភាពតាមប្រព័ន្ធសុខដុម-អាស៊ាន និងអង្គការគយពិភពលោក ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម ក៏ដូចជាការបំពេញកាតព្វកិច្ចរបស់កម្ពុជាក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មខាងលើតែប៉ុណ្ណោះ។

ក្នុងន័យនេះ ដើម្បីបំពេញកាតព្វកិច្ចរបស់កម្ពុជាក្រោមកិច្ចព្រមព្រៀងខាងលើ ដោយធានាសង្គតិភាពជាមួយតារាងពន្ធគយសុខដុមរបស់អាស៊ានឆ្នាំ២០១៧ និងសម្រួលដល់ការធ្វើពាណិជ្ជកម្ម កម្ពុជាត្រូវចេញនូវឯកសារគតិយុត្តិដើម្បីដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយខាងលើ តាមរយៈអនុក្រឹត្យ ដូចមានចែងនៅក្នុងមាត្រា៦នៃច្បាប់ស្តីពីគយរបស់កម្ពុជា។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ និងមេត្តាចុះហត្ថលេខាលើអនុក្រឹត្យ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជា-ណាចក្រកម្ពុជាស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>សូមគោរពជូនភ្ជាប់មកជាមួយ</u>:

- សេចក្តីព្រាងអនុក្រឹត្យជាភាសាខ្មែរចំនួន ០១ ច្បាប់
- កម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់កម្ពុជាតាមប្រព័ន្ធសុខដុម HS2017 ក្រោមកិច្ចព្រមព្រៀងអាស៊ាន-ចិនជាភាសាអង់គ្លេសចំនួន ០១ ច្បាប់

<u>ចម្លងជូន</u>:

- ក្រសួងពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ឯកសារ-កាលប្បវត្តិ

1-3.19

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ**...៣៧.....អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលី នៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ករម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយរបស់កម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារ នៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៤ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រាទី១.~**

ដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

កម្មវិធីកាត់បន្ថយ ឬលុបបំបាត់ពន្ធគយនេះ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រាទី២.~**

កម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ត្រូវអនុវត្តចំពោះតែទំនិញនាំចូលទាំងឡាយណាដែលមានដើមកំណើតនៅបណ្តាប្រទេសជាសមាជិកនៃភាគីតែប៉ុណ្ណោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃឧបសម្ព័ន្ធ ៣ (វិធានដើមកំណើតទំនិញ) នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

**មាត្រាទី៣.~**

អ្នកនាំចូលត្រូវគោរពតាមវិធាន និងនីតិវិធីនានា ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

**មាត្រាទី៤.~**

ខ្លឹមសារដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្ត ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលអនុក្រឹត្យនេះត្រូវបានចុះហត្ថលេខា។

**មាត្រា ៥.~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល</u>÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*Unofficial Translation*

**SUB-DECREE**
**ON**

**The Implementation of Tariff Reduction and /or Elimination Schedule of the Kingdom of Cambodia based on the ASEAN Harmonized Tariff Nomenclature 2017 under the Agreement on Trade in Goods of the Framework Agreement on Comprehensive Economic Cooperation between the Association of Southeast Asian Nations and the People's Republic of China**

**The Royal Government of Cambodia**

- Having seen the constitution of the Kingdom of Cambodia;
- Having seen the Royal Decree No. NS/RKT/0918/925 dated 6 September 2018 on the composition of the Royal Government of Cambodia;
- Having seen the Royal Decree No.NS/RKM/0618/012 dated 28 June 2018 on the Organization and Functioning of the Council of Ministers;
- Having seen the Royal Kram No. NS/RKM/0196/18 dated 24 January 1996 on the Establishment of the Ministry of Economy and Finance;
- Having seen the Royal Kram No. NS/RKM/0297/03 dated 24 February 1997 on the Promulgation of the Law on Fiscal Tax;
- Having seen the Royal Decree No. NS/RKM/0707/017 dated 20 July 2007 on the Promulgation of the Law on Customs;
- Having seen the Royal Kram No. NS/RKM/0904/002 dated 09 September 2004 on the Promulgation of the Law on the Adoption of the Protocol for Kingdom of Cambodia to join World Trade Organization
- Having seen Royal Decree No. NS/RKM/1207/033 dated 08 December 2007 on the promulgation of the Agreement on Trade in Goods of the Framework Agreement on Comprehensive Economic Cooperation between the Association of Southeast Asian Nations and the People's Republic of China;
- Having seen the Royal decree No. NS/RKM/0103/004 dated 20 January 2003 on the Promulgation of the Law on the Adoption for the Kingdom of Cambodia to join the Convention on the Establishment of Customs Cooperation Council;
- Having seen Royal Decree No. NS/RKM/0103/001 dated 20 January 2003 on the Promulgation of the Law on the Adoption for the Kingdom of Cambodia to join the International Convention on the harmonized Commodity Description and Coding System;
- Having seen the Sub-decree No. 488 HNKR. BK dated 16 October 2013 on the Organization and Function of the Ministry of Economy and Finance;
- Referring to the need of the Ministry of Economy and Finance

**Decided**

**Article 1.-**

To promulgate the Tariff Reduction and /or Elimination Schedule of the Kingdom of Cambodia, which not retroactively implemented based on the ASEAN Harmonized Tariff Nomenclature (AHTN) 2017 under the Agreement on Trade in Goods of the Framework Agreement on Comprehensive Economic Cooperation between the Association of Southeast Asian Nations and the People's Republic of China.

The Tariff Reduction / Elimination Schedule are set in the Annex of this Sub-decree.

**Article 2.-**

The Tariff Reduction and /or Elimination Schedule of the Kingdom of Cambodia as referred to the Annex of this Sub-decree can be applied on the conditions that goods are originated from Member Country of the Parties, with the Provision of Annex 3 (Rule of Origin) of the Agreement on Trade in Goods of the Framework Agreement on Comprehensive Economic Cooperation between the Association of Southeast Asian Nations and the People's Republic of China.

**Article 3.-**

Importers shall abide by Rules and Regulations set by the Ministry of Economy and Finance in implementing the Agreement on Trade in Goods of the Framework Agreement on Comprehensive Economic Cooperation between the Association of Southeast Asian Nations and the People's Republic of China.

**Article 4.-**

The Articles 1 and 2 above shall be implemented in 30 days after the date of signature of this Sub-decree.

**Article 5.-**

Any regulations contrary to this Sub-decree shall be invalidated.

**Article 6.-**

Minister in charge of the Council of Ministers, Minister of Economy and Finance, Ministers of all Ministries, and Heads of all Institutions shall be in charge of implementing this Sub-decree respectively from the date of signature.

Phnom Penh, 06 March 2019

**Prime Minister**

(Signature and Stamp)

**Samdech AkkaMohaSenaPadeiTecho HUN SEN**

Respectfully submitted to
Samdech AkkaMohaSenaPadeiTecho Prime Minister for Signature
**Deputy Prime Minister, Minister of Economy and Finance**

**AUN PORNMONIROTH**

**Copied for:**

- Ministry of Royal Palace
- Secretariat of the Constitutional Council
- Secretariat of the Senate
- Secretariat of the Parliament
- Cabinet Office of Samdech AkkaMohaSenaPadeiTecho Prime Minister of Kingdom of Cambodia
- Cabinet Office of Deputy Prime Ministers
- Municipal-Provincial Hall
- As Article 6
- Royal Gazette
- Document-Archives